

# សិទ្ធិមនុស្ស និងព្រឹត្តិការណ៍ទាក់ទិននឹងសេរីភាពក្នុងការបញ្ចេញមតិ

## រៀនសូត្រពីបទពិសោធ

## បញ្ជីពាក្យសរសេរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| AFEC | សម្ព័ន្ធភាពដើម្បីសេរីភាពក្នុងការបញ្ចេញមតិនៅប្រទេសកម្ពុជា |
| CCHR | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |


**ផលិតដោយ**

BUILDING CAPACITY WORLDWIDE
Pact Cambodia

**ឧបត្ថម្ភដោយ**

USAID
ជំនួយពីពលរដ្ឋអាមេរិក

ការបោះពុម្ពនេះអាចធ្វើទៅបាន តាមរយៈការគាំទ្រថវិកាដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក។ ទស្សនៈទាំងឡាយដែលបានបង្ហាញនៅក្នុងការបោះពុម្ពនេះ មិនឆ្លុះបញ្ចាំងទស្សនៈរបស់ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។

**សិទ្ធិមនុស្ស និងព្រឹត្តិការណ៍ទាក់ទិននឹងសេរីភាពក្នុងការបញ្ចេញមតិ៖** រៀនសូត្រពីបទពិសោធ

បោះពុម្ពផ្សាយលើកទី ១

កញ្ញា ២០០៦

យើងលើកទឹកចិត្តឱ្យលោកអ្នក ថតចម្លងផ្នែកណាមួយ ឬផ្នែកទាំងអស់នៃសៀវភៅនេះ និងចែកចាយទៅអ្នកដទៃទៀត។

# សេចក្តីផ្តើម

ឯកសារនេះរៀបរាប់ពីព្រឹត្តិការណ៍ទាំងឡាយនៅចុងឆ្នាំ ២០០៥ និងដើមឆ្នាំ ២០០៦ ទាក់ទងនឹងសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិមនុស្សនៅកម្ពុជា។ នៅក្នុងអំឡុងពេលនោះ អ្នករិះគន់ដ៏ល្បីល្បាញមួយចំនួនចំពោះរាជរដ្ឋាភិបាលត្រូវបានចាប់ខ្លួនក្រោមលេសមិនច្បាស់លាស់។ ជាការឆ្លើយតបទៅនឹងការចាប់ខ្លួននោះ សង្គមស៊ីវិលបានរួបរួមគ្នាជាសម្ព័ន្ធភាព និងបណ្តាញថ្មីៗដែលមានលក្ខណៈនវានុវត្តន៍ ហើយជនមួយចំនួនតូចបានប្រកាន់យកជំហររឹងប៉ឹង មានលក្ខណៈសារធារណៈ និងប្រកបដោយគោលការណ៍។

ឯកសារនេះ មានគោលបំណងពិនិត្យមើលមេរៀនទាំងឡាយដែលបានទទួលពីព្រឹត្តិការណ៍ទាំងនេះ និងជូនព័ត៌មានអំពីយុទ្ធសាស្ត្រតស៊ូមតិផ្សេងទៀត និងចលនារបស់ប្រជាពលរដ្ឋតាមរយៈអនុសាសន៍។ ឯកសារនេះឆ្លុះបញ្ចាំងពីគំនិត និងទស្សនៈរបស់អ្នកពាក់ព័ន្ធទាំងឡាយមកពីអង្គការមិនមែនរដ្ឋាភិបាល សហជីពកម្មករ សមាគមយុវជន ប្រព័ន្ធផ្សព្វផ្សាយ រដ្ឋាភិបាល សហគមន៍អន្តរជាតិ និងផ្នែកឯកជនដែលភាគច្រើនមានទីតាំងនៅក្រុងភ្នំពេញ។ ការយកចិត្តទុកដាក់ គឺផ្តោតជាបឋមលើរយៈពេលដែលចាប់ផ្តើមនៅក្នុងទិវាសិទ្ធិមនុស្សអន្តរជាតិ នៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៥ រហូតដល់ខែ មករា ឆ្នាំ ២០០៦។

# សាវតារ

ចាប់តាំងពីក្រោយកុបកម្មប្រឆាំងថៃនៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៣ មក អាជ្ញាធរកម្ពុជាកាន់តែមានការប្រុងប្រយ័ត្នលើការជួបប្រជុំសាធារណៈធំៗ។ ជាលទ្ធផល សេរីភាពក្នុងការបញ្ចេញមតិសាធារណៈរបស់មហាជន ត្រូវបានរិតត្បិតបន្ថែមទៀត ក្រោមលេសថាការជួបជុំគ្នាបែបនេះអាចរំខានដល់ច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ។ ក្នុងឆ្នាំ ២០០៥ គេឃើញមានការរិតត្បិតបន្ថែមទៀត លើសេរីភាពក្នុងការបញ្ចេញមតិ ដោយមានការចាប់ខ្លួនសមាជិកសភាមកពីគណបក្ស សម រង្ស៊ី គឺលោក ជាម ច័ន្ទនី ការដកអភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភាមួយចំនួននៃគណបក្សប្រឆាំង។ ដូចគ្នានេះដែរគេក៏ឃើញមានការកើនឡើងនូវការប្រើប្រាស់ច្បាប់បរិហាកេរ្តិ៍ ហើយរដ្ឋាភិបាលកាន់តែរសើបចំពោះការពិភាក្សាជាសាធារណៈអំពីបញ្ហាព្រំដែន។

អត្ថបទពីរទំព័របន្ទាប់នេះ បង្ហាញពីព្រឹត្តិការណ៍នៅចុងឆ្នាំ ២០០៥ និងនៅដើមឆ្នាំ ២០០៦ ដែលនាំឱ្យមានការរិតត្បិតសេរីភាពក្នុងការបញ្ចេញមតិ ការចាប់ខ្លួនបន្តបន្ទាប់ និងសកម្មភាពតស៊ូមតិធំៗ ដែលបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងការចាប់ខ្លួនទាំងនោះ។

# ប្រវត្តិនៃ

កញ្ញា

២០

លោក ម៉ម សូណង់ដូ ជាអ្នកយកព័ត៌មាន និងជាម្ចាស់វិទ្យុសម្បុកឃ្មុំ បានផ្សាយបទសំភាសន៏ ជាមួយលោក ស៊ាន ប៉េងសែ ប្រធានគណៈកម្មាធិការព្រំដែនកម្ពុជា ដែលមានមូលដ្ឋាននៅប្រទេសបារាំង ។ លោក ប៉េងសែ បានបញ្ចេញមតិ ដែលរិះគន់សន្ធិសញ្ញាព្រំដែនបន្ថែម ។ យោងតាមអង្គការសារព័ត៌មាន Reporters Without Borders លោក ម៉ម សូណង់ដូ បានស្នើឱ្យលោក ស៊ាន ប៉េងសែ ពន្យល់ពីសន្ធិសញ្ញាព្រំដែនទាំងឡាយ រវាងកម្ពុជា និងវៀតណាម ហើយ លោក ម៉ម សូណង់ដូ មិនបានវាយប្រហារ លើនាយករដ្ឋមន្ត្រី ហ៊ុន សែន ឡើយ ក្នុងបទសំភាសន៏នោះ ។

តុលា

១០

ការចុះហត្ថលេខាលើ សន្ធិសញ្ញាព្រំដែន បន្ថែមរវាងកម្ពុជា និងវៀតណាម ។



១១



លោក ម៉ម សូណង់ដូ ត្រូវបាន ចាប់ខ្លួន និងចោទប្រកាន់ ពីបទបរិហារកេរ្តិ៍ តាមមាត្រា ៦២ និង ៦៣ នៃច្បាប់អ៊ុនតាក់ ។ ការចោទប្រកាន់ គឺធ្វើតាមពាក្យបណ្តឹងចំពោះ បទសំភាសន៏ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០០៥ ដែលប្តឹងដោយរដ្ឋាភិបាល និងរដ្ឋសភា ។ ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា បានធ្វើសេចក្តីថ្លែងការណ៏មួយ ដែលមានចុះហត្ថលេខា ថ្កោលទោសដល់សន្ធិសញ្ញា ព្រំដែនបន្ថែមនោះ ។

១៥

លោក រ៉ុង ឈុន ប្រធាន សមាគមគ្រូបង្រៀនឯករាជកម្ពុជា និង ជាហត្ថលេខីមួយរូប នៃសេចក្តីថ្លែងការណ៏របស់ ក្រុមប្រឹក្សាឃ្លាំមើល កម្ពុជា ត្រូវបានចាប់ខ្លួន ។

មនុស្សបីនាក់ផ្សេងទៀតដែល បានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៏នោះដែរ បានចេញទៅក្រៅប្រទេសផុត នៅពេលដែលអាជ្ញាធរតាមរកចាប់ខ្លួនពួកគេ ។



២៤

សន្និសីទស្តីពីសេរីភាពក្នុង ការបញ្ចេញមតិនៅកម្ពុជា ត្រូវបានរៀបចំឡើង ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលនៅក្នុងនោះ "*សេចក្តីថ្លែងការណ៏ស្តីពីការអនុវត្តន៏សេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជា*" ត្រូវបាន ចុះហត្ថលេខាដោយ អង្គការចំនួន ៣១ ។

វិច្ឆិកា

២៨

សម្ព័ន្ធភាពដើម្បីសេរីភាព បញ្ចេញមតិនៅកម្ពុជា (AFEC) ត្រូវបានបង្កើត ឡើងដោយអង្គការជាង ២០ ។

៣០

AFEC ចាប់ផ្តើមចែកចាយ ប៊ូពណិល្បឿងចំនួន ៦០.០០០ ដែលជានិមិត្តរូប នៃការទាមទាររបស់អ្នកពាក់ នូវសេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជា ។

ព្រះមហាក្សត្រព្រះបាទ នរោត្តម សីហមុនី ឡាយព្រហស្ថលេខា លើសន្ធិសញ្ញាព្រំដែន បន្ថែម ជាមួយវៀតណាម ។



២



តំណាងពិសេសនៃអគ្គលេខាធិការ អង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្សនៅកម្ពុជា ជួបជាមួយលោកម៉ម សូណង់ដូ និង លោក រ៉ុង ឈុន នៅពន្ធនាគារព្រៃស ។

១០

ទិវាសិទ្ធិមនុស្ស មានមនុស្សចូលរួម ចំនួន ១០.០០០ នាក់ ដែលក្នុងនោះ មានតំណាងមកពីក្រុមសិទ្ធិមនុស្ស និងអភិវឌ្ឍន៏ អង្គការកម្មករ និងក្រុមយុវជន ។ បដាមួយដែលតាំងនៅពេលព្រឹក ដែលមានមតិសរសេរដោយដៃ ដែលរិះគន់រដ្ឋាភិបាល ត្រូវបានដកហូត ក្រោយមានការតវ៉ាពីអាជ្ញាធរ ។



# ព្រឹត្តិការណ៍







ធ្នូ

**១៣** កិច្ចប្រជុំមួយបានធ្វើឡើងជាមួយអ្នករៀបចំទិវាសិទ្ធិមនុស្សអន្តរជាតិ និងអាជ្ញាធរក្រុងភ្នំពេញ ដែលនៅក្នុងនោះ លោក យ៉េង វីរៈ ដែលជានាយកប្រតិបត្តិមជ្ឈមណ្ឌលអប់រំច្បាប់កម្ពុជា និងជាប្រធានរៀបចំ បានឲ្យល់ថា ក្រោយការតវ៉ា បដានោះត្រូវបានដកចេញដោយរដ្ឋាភិបាល។

**៣១** លោក កឹម សុខា នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និង លោក យ៉េង វីរៈ ត្រូវ បានចាប់ខ្លួននៅការិយាល័យរបស់ពួកគាត់។



មករា

**៤** លោក ប៉ា ងួនទៀង អនុប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ត្រូវបានចាប់ខ្លួន។

**៥** ការតវ៉ារបស់សហភាពអឺរ៉ុបទាក់ទងនឹងសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

**៧** ការតវ៉ានៅពន្ធនាគារព្រៃស : អ្នកគាំទ្រយករបស់របរ ជូនអ្នកជាប់ឃុំឃាំង និងព្រលែងចាបចំនួន ១០០ ជានិមិត្តរូបនៃសេរីភាព។ ពិធីបែបនេះត្រូវបានធ្វើឡើងម្តងទៀត នៅថ្ងៃសៅរ៍បន្ទាប់ ដោយមានអ្នកគាំទ្រ ១៥០ នាក់។

**១១** លោក យ៉េង វីរៈ ត្រូវបានដោះលែងពីការឃុំខ្លួន មុនកាត់ទោស។



**១៧** **អនុរដ្ឋមន្ត្រីការបរទេសអាមេរិក** Christopher Hill **ជួបជាមួយនាយករដ្ឋមន្ត្រី ហ៊ុនសែន។** លោក ម៉ម សូណង់ដូ រ៉ុង ឈុន, កឹម សុខា និង ប៉ា ងួនទៀង ត្រូវបានដោះលែង ពីការឃុំខ្លួនមុនកាត់ទោស។

**២៣** លោក កឹម សុខា, ម៉ម សូណង់ដូ និង រ៉ុង ឈុន យល់ព្រមសរសេរទៅកាន់នាយករដ្ឋមន្ត្រីដើម្បីពន្យល់ពីការចូលរួមរបស់ពួកគាត់នៅក្នុងសកម្មភាពនៃសេរីភាពក្នុងការបញ្ចេញមតិ។



**២៤** ឮថានាយករដ្ឋមន្ត្រីបានជូនដំណឹងដល់គណៈរដ្ឋមន្ត្រី ឱ្យទម្លាក់ចោលបណ្តឹងបរិហារកេរ្តិ៍។

**៣០** នាយករដ្ឋមន្ត្រីប្រកាសថា ការដក ឬការព្យួរករណីទាំងនោះ គឺមិនអាចធ្វើបានទេ ដោយសារករណីទាំងនោះបានចូលដល់ដំណាក់កាលស៊ើបអង្កេតរួចទៅហើយ។

កុម្ភៈ

**២៨** បណ្តឹងរបស់រដ្ឋាភិបាលចំពោះលោក ម៉ម សូណង់ដូ រ៉ុង ឈុន, កឹម សុខា ប៉ា ងួនទៀង និង យ៉េង វីរៈ ត្រូវបានដកចេញ ទោះបីជាការចោទប្រកាន់បទព្រហ្មទណ្ឌ ស្ថិតនៅតុលាការក៏ដោយ។




ប្រព័ន្ធផ្សព្វផ្សាយជាតិ និងអន្តរជាតិដែលបានផ្សាយពីព្រឹត្តការណ៍ចាប់ខ្លួនសកម្មជនសិទ្ធិមនុស្ស

# ការឆ្លើយតបទៅនឹងព្រឹត្តិការណ៍ទាំងនេះ

ព្រឹត្តិការណ៍តស៊ូមតិធំៗបានកើតឡើង ជាការឆ្លើយតបទៅនឹងការចាប់ខ្លួនសកម្មជនសិទ្ធិមនុស្សទាំងនោះ។ សកម្មភាពទាំងនេះ បានចាប់ផ្តើមដោយការប្រារព្ធធ្វើសន្និសីទស្តីពីសេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជា នៅចុងខែ តុលា ឆ្នាំ ២០០៥ ហើយដែលផ្តើមចេញពីសន្និសីទនោះ សម្ព័ន្ធភាពដើម្បីសេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជា (AFEC) ត្រូវបានបង្កើតឡើង។ ការឆ្លើយតបទៅនឹងការចាប់ខ្លួនទាំងនោះរួមមាន តាំងពីសេចក្តីថ្លែងការណ៍ និងលិខិតជាបុគ្គល កិច្ចប្រជុំការទូតរវាងមន្ត្រីទាំងឡាយ រហូតដល់វេទិកា និងការតវ៉ាធំៗ ទាំងនៅក្នុងក្រុងភ្នំពេញ តាមខេត្ត និងនៅបរទេស។ ការឆ្លើយតបទាំងនេះ កើតចេញពីអង្គការ និងបុគ្គលមួយចំនួន ទាំងនៅក្នុងប្រទេសកម្ពុជា និងនៅបរទេស។ ជាលទ្ធផលគេឃើញមានសេចក្តីរាយការណ៍ព័ត៌មានជាច្រើន ទាំងក្នុងស្រុកក៏ដូចជាអន្តរជាតិ ស្តីពីការចាប់ខ្លួននោះ ក៏ដូចជាសកម្មភាពតស៊ូមតិដែលបានកើតឡើង នៅពេលក្រោយមក។

ថ្វីបើគេបានទទួលមេរៀនជាច្រើនពីសកម្មភាពទាំងនេះក្តី ក៏គេមិនអាចកំណត់បាននូវឥទ្ធិពលនៃសកម្មភាពជាក់លាក់ណាមួយលើលទ្ធផលឡើយ។ ប្រការនេះ គឺដោយសារគេមិនបានដឹងពីមូលហេតុនៅពីក្រោយការសម្រេចចិត្តដោះលែងសកម្មជនទាំងនោះ។ ដូចគ្នានេះដែរ ដោយសារសកម្មភាពទាំងនោះដំណើរការជាផ្លូងមួយ គេក៏មិនអាចញែកឥទ្ធិពលជាក់លាក់ដោយឡែកបានដែរ។

### សន្និសីទស្តីពីការបញ្ចេញមតិនៅកម្ពុជា
*ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥*
**រៀបចំដោយ :** CCHR
**លទ្ធផល:** នាំឱ្យមានការបង្កើតសម្ព័ន្ធភាពដើម្បីសេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជា (AFEC) ។ អង្គការចំនួន ៣១ បានចុះហត្ថលេខាលើ "សេចក្តីថ្លែងការណ៍ស្តីពីការអនុវត្តន៍សេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជា" និងបានបង្រួបបង្រួមអង្គការកម្មករ និងក្រុមសិទ្ធិមនុស្ស នៅក្នុងសម្ព័ន្ធភាពថ្មីមួយ ។

### លិខិតរបស់អ្នកទិញសម្លៀកបំពាក់ជូនចំពោះនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ( ក្រសួងការងារ ពាណិជ្ជកម្ម និងមហាផ្ទៃ)
*ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៦*
**រៀបចំដោយ :** អង្គការអាជីវកម្មដើម្បីការទទួលខុសត្រូវសង្គម និងអង្គការផ្សេងទៀត ។
**លទ្ធផល :** លិខិតបានអំពាវនាវឱ្យដកការចោទប្រកាន់លើបទបរិហារកេរ្តិ៍ ។

### យុទ្ធនាការបូពណ៌លឿង
*ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៥*
**រៀបចំដោយ :** AFEC
**លទ្ធផល :** បានចែកចាយបូពណ៌លឿងចំនួន ១០០ ០០០ ដែលតំណាងឱ្យការគាំទ្រដល់សេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជា ។
**យោបល់ :** អ្នករៀបចំជួបការលំបាកខ្លះក្នុងការចែកចាយបូ ។ អ្នកខ្លះខ្លាចមិនហ៊ានពាក់បូ ។ គេក៏យល់ឃើញផងដែរថា ឥទ្ធិពលនៃយុទ្ធនាការនេះគឺមានតែនៅក្រុងភ្នំពេញ ។



*"យុទ្ធនាការបូពណ៌លឿង គឺជានិមិត្តរូបដ៏ល្អមួយ ប៉ុន្តែវានៅខ្វះការចាប់អារម្មណ៍ ដោយសារខ្ញុំគិតថា មិនសូវមានមនុស្សច្រើន ដែលដឹងអំពីយុទ្ធនាការនេះ ហើយពួកគេមិនយល់ ថាតើវាតំណាងឱ្យអ្វី ។ ហេតុនេះ ជាការប្រសើរ គួរផ្សព្វផ្សាយដល់សាធារណជន អំពីអត្ថប្រយោជន៍ និងអត្ថន័យរបស់វា ។ "* **(សិស្សសាលា)**

*"យុទ្ធនាការបូពណ៌លឿងមិនសូវមានឥទ្ធិពលទេ ដោយសារវាមិនមានការលើកកំពស់ការយល់ដឹង ឱ្យបានទូលាយជូនដល់សាធារណជន ។ វាអាចប្រសើរជាងនេះ ប្រសិនបើមានក្រុមវាគ្មិនស្ម័គ្រចិត្តដែលអាចទាក់ទងអង្គការនានា ហើយសុំឱ្យអង្គការទាំងនោះពាក់បូ ដោយមានការយល់ដឹងច្បាស់អំពីអត្ថន័យរបស់វា ។ "* **(នាយក NGO)**

### ញត្តិផ្តិតមេដៃទាមទារសុំឱ្យមានសេរីភាពក្នុងការបញ្ចេញមតិ
*ខែ មករា និង កុម្ភៈ ឆ្នាំ ២០០៦*
**រៀបចំដោយ :** CCHR ដែលជួយដោយក្រុមប្រឹក្សាយុវជនកម្ពុជា និងអង្គការកម្មករ
**លទ្ធផល :** ស្នាមមេដៃជាង ១៨០.០០០ ត្រូវបានគេប្រមូលមុនពាក់កណ្តាលខែ កុម្ភៈ ។



**យោបល់:** គេជួបប្រទះការលំបាកខ្លះ ជាមួយនឹងការប្រឆាំងពីអាជ្ញាធរ ហើយក្រុមខ្លះមិនយល់ដឹងពីយុទ្ធនាការនេះ ។
*"ការប្រមូលស្នាមមេដៃគឺមានប្រសិទ្ធភាព និងទាន់ពេល ដោយសារវាផ្តល់ឱកាសដល់អ្នកគាំទ្រសេរីភាពក្នុងការនិយាយស្តី ដើម្បីចូលរួម និងសម្តែងមតិរបស់ខ្លួន ។ យុទ្ធនាការផ្តិតមេដៃ បានប្រាប់អ្នកធ្វើគោលនយោបាយថា មានការគាំទ្រពីប្រជាពលរដ្ឋ ហើយថាប្រជាពលរដ្ឋសុខចិត្តចុះឈ្មោះរបស់ខ្លួននៅក្នុងចលនានោះ ។ យុទ្ធនាការនោះ បានធ្វើអោយព្រះមហាក្សត្រខ្មែរទ្រង់ជ្រាបពីបញ្ហាដែលកើតមានឡើង ។ "* **(នាយក NGO)**

### ការអុជទៀននៅមុខសេតវិមាន កូនស្រីរបស់លោក កឹម សុខា ផ្តល់បទសំភាសន៍តាមវិទ្យុអាស៊ីសេរី និង វិទ្យុសម្លេងសហរដ្ឋអាមេរិក
*ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៦*



**រៀបចំដោយ :** ក្រុមប្រឹក្សាបង្រួបបង្រួមជាតិកម្ពុជាអន្តរជាតិ ( មានទីតាំងនៅសហរដ្ឋអាមេរិក) ជាមួយកូនស្រីរបស់ លោក កឹម សុខា ។
**លទ្ធផល:** ជនជាតិអាមេរិកដែលមានដើមកំណើតខ្មែរ និងអ្នកគាំទ្រចំនួន ៧៥ នាក់ បានចូលរួមក្នុងការអុជទៀននោះ ។

### ការសួរសុខទុក្ខនៅពន្ធនាគារព្រៃស
*ថ្ងៃទី ៧ ខែ មករា និងថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០០៦*
**រៀបចំដោយ :** AFEC និង អង្គការដទៃទៀត ។ ប្រតិភូដឹកនាំដោយក្រុមគ្រួសាររបស់អ្នកជាប់ឃុំ ។



**លទ្ធផល :** ការសួរសុខទុក្ខនីមួយៗមានមនុស្សចូលរួមពី ៥០ ដល់ ១៥០ នាក់ មកពីអង្គការសិទ្ធិមនុស្ស មន្ត្រី NGO និងសហជីព ។ មានការបង្ហោះប៉េងប៉ោង និងលែងចាប ជានិមិត្តរូបនៃការដោះលែង ។
**យោបល់:** ក្រុមគ្រួសារត្រូវបានដាក់នៅជួរមុខនៃការតវ៉ា ។ គេឃើញមានការយកចិត្តទុកដាក់លើបុគ្គល និងជនរងគ្រោះជាជាងលើអង្គការ ។
*"ការសួរសុខទុកនៅពន្ធនាគារព្រៃសមានឥទ្ធិពល ដោយសារវាបង្ហាញពីការប្តេជ្ញាចិត្តរបស់ប្រជាពលរដ្ឋក្នុងការទាក់ទងជាមួយអ្នកនៅក្នុងពន្ធនាគារ និងក្នុងការបង្ហាញអ្នកនៅខាងក្រៅនូវការប្តេជ្ញាចិត្តរបស់សកម្មជនសំខាន់ៗ ។ វាបានបង្ហាញដល់សហគមន៍អន្តរជាតិថា មានអ្នកប្តេជ្ញាចិត្តដែលហ៊ានប្រថុយជីវិតរបស់ខ្លួនដើម្បីបញ្ចេញមតិ និងថា បញ្ហានេះមានសារៈសំខាន់ចំពោះប្រជាពលរដ្ឋខ្មែរ ។ "* **(នាយក NGO)**

# តស៊ូមតិ

## កំណើនវេទិកាសាធារណៈរបស់ CCHR

*ខែ មករា ឆ្នាំ ២០០៦*

វេទិកា ៨ បានធ្វើនៅក្នុងខែ មករា

**រៀបចំដោយ** : CCHR



**លទ្ធផល :** មានអ្នកចូលរួមពី ២០០ ដល់ ៨០០ នាក់ ដោយមានការថ្លែងសុន្ទរកថា ដោយមន្ត្រីអាមេរិក និងឯកអគ្គរដ្ឋទូតអាមេរិក។ វេទិកាទាំងនេះត្រូវបានធ្វើឡើងដើម្បីផ្សព្វផ្សាយពីការចាប់ខ្លួន ប្រមូលស្នាមមេដៃ និងផ្សព្វផ្សាយយុទ្ធនាការបួពណ៌លឿង។ ប្រព័ន្ធផ្សព្វផ្សាយជាតិ និងអន្តរជាតិ បានផ្សាយដំណឹងអំពីវេទិកាទាំងនេះ។

**យោបល់:** វេទិកាទាំងនេះ គឺជាមធ្យោបាយដ៏សំខាន់មួយក្នុងការផ្សារភ្ជាប់ប្រជាពលរដ្ឋនៅតំបន់ជនបទ និងបានដើរតួនាទី ដើម្បីរក្សាបញ្ហានេះឱ្យទទួលការចាប់អារម្មណ៍ បានយូរ។

## សេចក្តីថ្លែងការណ៍របស់ធនាគារពិភពលោក

*ថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០០៦*



**ទិន្នផល :** សេចក្តីថ្លែងការណ៍បានចាត់ទុកការប្រើច្បាប់ព្រហ្មទណ្ឌ ដើម្បីប្តឹងផ្តល់ការសម្តែងមតិជំទាស់លើរឿងនយោបាយ និងគោលនយោបាយ ថាជាការបញ្ជូនសារដ៏គួរឱ្យបារម្ភមួយ ដល់វិនិយោគិនដែលចង់រកស៊ីនៅស្រុកខ្មែរ និងដល់ដៃគូអភិវឌ្ឍន៍។

## ការតវ៉ារបស់សហភាពអឺរ៉ុប

*ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០០៦*



ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ និងបារាំង និងតំណាងនៃប្រតិភូគណៈកម្មការអឺរ៉ុបប្រចាំនៅកម្ពុជា។

**លទ្ធផល :** ប្រតិភូនេះបានជួបជាមួយរដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ពួកគេបានដាក់ជូនការតវ៉ាការទូតមួយ ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដោយសារមានការចាប់ខ្លួនទាំងនេះ។

**យោបល់:** នៅក្នុងជំនួបនេះ ប្រតិភូបានសង្កត់ធ្ងន់ពីកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា។

## ការទូតផ្ទាល់ខ្លួនៈ ការចូលជួបឯកអគ្គរដ្ឋទូតទាំងឡាយប្រចាំនៅភ្នំពេញ

*ខែ មករា ឆ្នាំ ២០០៦*

លោកស្រី តែ ចាន់មនោ ភរិយាលោក កឹម សុខា

**លទ្ធផល :** ក្រោយពេលដែលស្វាមីរបស់លោកស្រីត្រូវបានចាប់ខ្លួន លោកស្រី តែ ចាន់មនោ បានជួបឯកអគ្គរដ្ឋទូតចំនួន ៨ រូប ដែលក្នុងនោះរួមមានឯកអគ្គរដ្ឋទូតជប៉ុន អាល្លឺម៉ង់ ថៃ និង សឹង្ហបុរី។

**ការសង្កេត :** បើទោះជាគេមិនដឹងពីឥទ្ធិពលពិតប្រាកដនៃជំនួបទាំងនោះក្តី ប្រការដែលលោកស្រីត្រូវបានឱ្យចូលជួបនេះ បង្ហាញនូវភាពម៉ឺងម៉ាត់របស់អ្នកការទូត ចំពោះការចាប់ខ្លួននោះ។ ការជួបទាំងនោះត្រូវបានផ្សព្វផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក។

## តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

*ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៥*

*ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៥*



**លទ្ធផល :** តំណាងពិសេសនៃអគ្គលេខាធិការ អង្គការសហប្រជាជាតិ បានជួបជាមួយរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានសួរសុខទុក្ខលោក ម៉ម សូណង់ដូ និងលោក រ៉ុង ឈុន នៅព្រៃស និង លោក ជាម ច័ន្ទនី នៅក្នុងពន្ធនាគារយោធា។ តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិបានបង្ហាញការបារម្ភរបស់លោកអំពីសេរីភាពក្នុងការបញ្ចេញមតិ និងការអនុវត្តសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា។

## ទស្សនកិច្ចរបស់ឥស្សរជនបរទេស

*ខែ មករា ឆ្នាំ ២០០៦*



**លទ្ធផល :** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ស៊ុយអែដ បានជួបសួរសុខទុក្ខលោក កឹម សុខា នៅពន្ធនាគារព្រៃស ហើយក៏បានជួបផងដែរជាមួយនឹងមន្ត្រីរាជរដ្ឋាភិបាលកម្ពុជា ដែលរួមមាននាយករដ្ឋមន្ត្រី ហ៊ុន សែន។ ឧបការីការបរទេសសហរដ្ឋអាមេរិក Christopher Hill បានជួបជាមួយ នាយករដ្ឋមន្ត្រី ហ៊ុន សែន។

**យោបល់:** អ្នកផ្តល់ព័ត៌មានមួយចំនួននៅក្នុងការសិក្សានេះវាយតម្លៃថា ទស្សនកិច្ច ដោយ Christopher Hill គឺជាកត្តាសំខាន់បំផុត ក្នុងការដោះលែងសកម្មជនទាំងនោះ។

# តើអ្វីមានប្រសិទ្ធភាព ហើយអ្វីគ្មានប្រសិទ្ធភាព?

## ចំណុចខ្លាំង

### កិច្ចសហការ និងការសម្របសម្រួលគ្នា

អង្គការសិទ្ធិមនុស្ស និងសង្គមស៊ីវិល បានសហការគ្នាជាមួយដៃគូថ្មី និងដៃគូដែលមានស្រាប់ ដូចជាសហគមន៍អន្តរជាតិ ប្រព័ន្ធផ្សព្វផ្សាយ និងក្រុមផ្សេងទៀត។ នៅចុងឆ្នាំ ២០០៥ និងដើមឆ្នាំ ២០០៦ ភាពជាដៃគូថ្មី ត្រូវបានបង្កើតឡើងប្រកបដោយជោគជ័យ រវាងអង្គការសិទ្ធិមនុស្ស អង្គការអភិវឌ្ឍន៍សហជីពកម្មករ និងសង្គមស៊ីវិលដ៏ទូលំទូលាយ ដែលរួមមានសមាគមយុវជនផងដែរ ។



កម្មករ និស្សិត និងសកម្មជនសិទ្ធិមនុស្សជាង ១០ ០០០ នាក់ បានប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ នៅស្តាតអូឡាំពិក

ចលនានៃការចាប់ខ្លួនលើកទីពីរ ដោយរដ្ឋាភិបាលដែលធ្វើឡើងក្រោយទិវាសិទ្ធិមនុស្សអន្តរជាតិ ដែលមើលទៅដូចជាមានលក្ខណៈមិនប្រឈមមុខ (តែមានទ្រង់ទ្រាយកាន់តែធំ) ត្រូវបានមនុស្សជាច្រើនចាត់ទុកថា គឺជាទង្វើជ្រុលហួសហេតុ។ ប្រការនេះ បានដើរតួជាកម្លាំងចលករដែលជំរុញឱ្យមានការចូលរួមកាន់តែច្រើនពីសំណាក់សហជីព និងសហព័ន្ធកម្មករនៅក្នុងបញ្ហាសិទ្ធិមនុស្ស ព្រមទាំងការធ្វើសកម្មភាពរួមគ្នា រវាងអង្គការសិទ្ធិមនុស្ស និងអង្គការអភិវឌ្ឍន៍មិនមែនរដ្ឋាភិបាល។

**ឧទាហរណ៍ :** ក្នុងចំណោមញត្តិដែលមានស្នាមមេដៃ ១៨០ ០០០ ដែលប្រមូលបាន ក្រុមប្រឹក្សាយុវជនកម្ពុជា (ដែលជាអង្គការយុវជនថ្មីមួយ) ប្រមូលបានស្នាមមេដៃចំនួន ១៤ ៧៥៦ ដែលការណ៍នេះបង្ហាញនូវការចូលរួម និងកិច្ចសហប្រតិបត្តិការដ៏សកម្មរបស់តួអង្គថ្មីមួយ។ ។

ក្រុមនីមួយៗមានជំនាញ និងចំណុចខ្លាំងខុសៗគ្នា ដូចជាសហជីពកម្មករមានរចនាសម្ព័ន្ធសមាជិកភាពដ៏ធំទូលាយ រីឯអង្គការសិទ្ធិមនុស្សមិនមែនរដ្ឋាភិបាល មានបទពិសោធច្រើននៅក្នុងការតស៊ូមតិរបស់ខ្លួន។ កិច្ចសហប្រតិបត្តិការរបស់ពួកគេ បានរីកដុះដាលជាស្វ័យប្រវត្តិ ដោយមានការជួយជ្រោមជ្រែងពីសំណាក់បុគ្គលទាំងឡាយដែលពាក់ព័ន្ធ នៅក្នុងក្រុមលើសពីមួយ។

## សេចក្តីក្លាហាន និងជំហរជាគោលការណ៍

ថ្វីបើមានសកម្មជនមួយចំនួនតូចសំរេចចិត្តលាក់ខ្លួន ឬចាកចេញពីប្រទេសក្តី ក៏សកម្មជនដទៃទៀត បានសំរេចចិត្តប្រកបដោយមនសិការក្នុងការស្ថិតនៅចេញមុខជាសាធារណៈ។ លោក យ៉េង វីរៈ និង លោក គឹម សុខា បានសំរេចមិនចាកចេញពីប្រទេសកម្ពុជាឡើយ បើទោះជាពួកគាត់សង្ស័យថា អាជ្ញាធរ នឹងព្យាយាមចាប់ខ្លួនពួកគាត់ក៏ដោយ។ អ្នកដឹកនាំសហជីពមួយរូបដែលគេជឿថា ត្រូវអាជ្ញាធរគំរាម ចាប់ខ្លួន បានលេចមុខនៅឯពន្ធនាគារព្រៃសនៅថ្ងៃសៅរ៍ ក្នុងពិធីព្រលែងចាប និងបង្ហោះប៉េងប៉ោង ហើយ បានថ្លែងសុន្ទរកថាមួយ។ ពួកគេចេញសេចក្តីថ្លែងការណ៍ ដែលផ្អែកលើគោលការណ៍នៃសេរីភាពក្នុងការ បញ្ចេញមតិ និងការបង្កើតសមាគម។ ជំហរប្រកបដោយគោលការណ៍ទាំងនេះ បានដើរតួជាគំរូមួយសំរាប់ សកម្មជនដទៃទៀត ហើយបន្ទាប់មកសម្ព័ន្ធភាពនោះគាំទ្រពួកគេ និងរួបរួមគ្នានៅជុំវិញជំហររបស់ពួកគេ។

## វិធីប្រាស្រ័យទាក់ទងបែបថ្មី ប្រព័ន្ធផ្សព្វផ្សាយ និងសហគមន៍អន្តរជាតិ

គេបានទាក់ទង និងធ្វើការគៀងគរអ្នកស្តាប់បានកាន់តែច្រើន នៅក្នុងអំឡុងពេលធ្វើសកម្មភាព ទាំងនេះ ដោយការប្រើវិធីប្រាស្រ័យទាក់ទងបែបថ្មី ដូចជាការផ្ញើសារតាមទូរស័ព្ទចល័តដែលផ្តល់ព័ត៌មាន ពិស្តារអំពីវេទិការបស់ CCHR និងព័ត៌មានអំពីព្រឹត្តិការណ៍ថ្មីៗ។ វិបសាយអ៊ីនធឺណិតត្រូវបានបង្កើតឡើង (ឧទាហរណ៍ដូចជា វិបសាយ freesokha) ហើយវេទិកាពិភាក្សាតាមអ៊ីនធឺណិតចាប់ផ្តើមមានសកម្មភាព។ ឧទាហរណ៍ អ្នករៀបចំយុទ្ធនាការផ្តិតមេដៃ បានប្រើការផ្ញើសារតាមទូរស័ព្ទចល័ត ដើម្បីទទួលតួលេខថ្មីៗ អំពីការរាប់ញត្តិនៅតាមខេត្ត។

ការកើនឡើងនូវការយកព័ត៌មានស្តីពីការតស៊ូមតិមុនពេលដោះលែងសកម្មជនទាំងនោះ ត្រូវបាន គេមើលឃើញថាជាភស្តុតាងមួយនៃកំណើនប្រកបដោយប្រសិទ្ធភាពនូវការតាមដានប្រព័ន្ធផ្សព្វផ្សាយ។ លើសពីនេះទៀត យុទ្ធសាស្ត្រទាំងឡាយត្រូវបានគេជ្រើសរើសដើម្បីដាក់ឥទ្ធិពលលើតួអង្គសំខាន់ៗ ដែល អាចមានឥទ្ធិពលខ្លាំងលើការសំរេចចិត្តរបស់អាជ្ញាធរ ដូចជាទំនាក់ទំនងសាធារណៈជាមួយក្រុមហ៊ុន ទិញសម្លៀកបំពាក់ធំៗ ដែលជាលទ្ធផល គេឃើញមានការផ្ញើលិខិតជាឯកជនមួយ ពីក្រុមហ៊ុនទិញសម្លៀក បំពាក់នៅសហរដ្ឋអាមេរិក ផ្ញើជូនអាជ្ញាធរខ្មែរ។ ព្រឹត្តិការណ៍នេះកើតឡើង ស្របគ្នានឹងដំណើរទស្សនកិច្ចជា យុទ្ធសាស្ត្រមួយ របស់ឧបការីការបរទេសសហរដ្ឋអាមេរិក។ គេយល់ថា សហគមន៍អន្តរជាតិបានដើរតួ ជាអន្តរការីមួយដ៏សំខាន់ រវាងសង្គមស៊ីវិល និងរដ្ឋាភិបាល។

*"កិច្ចសហការជាមួយសហគមន៍អន្តរជាតិ មានសារៈសំខាន់ខ្លាំងណាស់ ដោយសារយើងចាំបាច់ ត្រូវសាងស្ពានមួយភ្ជាប់ទៅនឹងពិភពលោកខាងក្រៅ ...ហើយប្រព័ន្ធផ្សព្វផ្សាយគឺជាកូនសោដ៏សំខាន់។"*

**(បុគ្គលិកជាន់ខ្ពស់ NGO មួយរូប)**

### ការធ្វើចលនាមហាជនដោយគ្មានការប្រឈមមុខ

ដោយសារប្រវត្តិសាស្ត្រខ្មៅងងឹតរបស់កម្ពុជា ជាទូទៅគេសង្កេតឃើញថា មានការរារែកក្នុងការចូលរួមតវ៉ាដែលមានលក្ខណៈប្រឈមមុខខ្លាំង ដូចជាការតវ៉ាមហាជនដែលនាំឱ្យមានការចាប់ខ្លួនទាំងហ្វូងៗ។ យុទ្ធនាការបូពណ៌លឿង និងការប្រមូលស្នាមមេដៃ ឆ្លុះបញ្ចាំងពីសារៈសំខាន់នៃកិច្ចប្រឹងប្រែងតស៊ូមតិ ដែលសមស្របទៅនឹងវប្បធម៌ និងប្រវត្តិសាស្ត្រ។

*"ការបង្ករឿងនឹងមិនមានប្រសិទ្ធភាពឡើយ។ ជាពិសេស នៅក្នុងវប្បធម៌កម្ពុជា គ្រាន់តែពាក្យមួយម៉ាត់ អាចបញ្ឆេះឱ្យមានវិវាទមួយបាន។"* (**អ្នកបម្រើការងារអភិវឌ្ឍន៍ជាតិកម្ពុជាមួយរូប**)



អ្នកចូលរួមនៅក្នុងការដើរក្បួនសេរីភាពដើម្បីនិយាយស្តី

អ្នកឆ្លើយតបជាច្រើន បានគូសបញ្ជាក់ពីជោគជ័យនៃយុទ្ធនាការប្រមូលស្នាមមេដៃ។ សារនៃយុទ្ធនាការនេះមានភាពច្បាស់លាស់ហើយប្រជាពលរដ្ឋខ្មែរ មានទម្លាប់ប្រើវិធីផ្តិតមេដៃនេះ ដើម្បីបញ្ចេញយោបល់របស់ខ្លួន។

បើទោះជាមានការរិះគន់ថា បូពណ៌លឿងមិនបានជ្រៀតចូលទៅដល់តំបន់ក្រៅក្រុងភ្នំពេញក្តី ក៏វាបានបង្ហាញនូវនិមិត្តរូបដ៏មានឥទ្ធិពលមួយ តំណាងឱ្យបំណងប្រាថ្នារបស់ប្រជាពលរដ្ឋខ្មែរដែលចង់បានសេរីភាពក្នុងការបញ្ចេញមតិ។ *"បូពណ៌លឿង គឺជាសារមួយដែលស្របគ្នានឹងបរិបទនៃប្រទេសកម្ពុជា និងគាំទ្រអំពើអហិង្សា។"* (**បុគ្គលិកជាន់ខ្ពស់ NGO មួយរូប**)

## បញ្ហាប្រឈម

### កង្វះភាពជាអ្នកដឹកនាំ ការភ័យខ្លាច និងការមិនទុកចិត្តគ្នា

ចលនានៃការចាប់ខ្លួនលើកទីមួយនៅក្នុងខែ តុលា ឆ្នាំ ២០០៥ បានធ្វើឱ្យអ្នកដឹកនាំសិទ្ធិមនុស្សមួយចំនួនចាកចេញពីប្រទេសជាបណ្តោះអាសន្ន។ បន្ទាប់មក ចលនានៃការចាប់ខ្លួនលើកទីពីរ បាននាំឱ្យមានការភ័យខ្លាចរាលដាលក្នុងចំណោមសកម្មជន និងបុគ្គលទាំងឡាយដែលពាក់ព័ន្ធនឹងសកម្មភាពតស៊ូមតិ។ ការភ័យខ្លាចនេះបានបណ្តាលឱ្យសកម្មជនសិទ្ធិមនុស្សចាកចេញពីប្រទេស ឬលាក់ខ្លួនបន្ថែមទៀត។ ជាលទ្ធផល សកម្មភាពតស៊ូមតិមួយចំនួនត្រូវផ្អាក ដោយសារតែកង្វះខាតភាពជាអ្នកដឹកនាំពីសំណាក់អង្គការសង្គមស៊ីវិលធំៗ ដែលហ៊ានបញ្ចេញមតិ។

## រចនាសម្ព័ន្ធស្ថាប័នដែលមានលក្ខណៈជាបុគ្គល

មានការយល់ឃើញថា អវត្តមានរបស់អ្នកដឹកនាំក្នុងអំឡុងព្រឹត្តិការណ៍ទាំងនេះ បាននាំឱ្យបាត់អំណាចគ្រប់គ្រងនៅក្នុងអង្គការខ្លះដែលមានភាពទន់ខ្សោយខាងស្ថាប័ន។ ជាទូទៅ NGO នៅក្នុងប្រទេសកម្ពុជា គឺពឹងផ្អែកលើកេរ្តិ៍ឈ្មោះរបស់មេដឹកនាំរបស់ខ្លួន ហើយនៅពេលដែលមេដឹកនាំចាកចេញ អង្គការមានការលំបាកក្នុងការរកអ្នកដឹកនាំថ្មីចេញពីបុគ្គលិកដែលមានស្រាប់ ឬអ្នកពីខាងក្រៅ។ ប៉ុន្តែប្រការនេះក៏មានផលជាវិជ្ជមានមួយផងដែរ នៅក្នុងបរិបទនៃព្រឹត្តិការណ៍ទាំងនេះ។ អវត្តមាននៃមេដឹកនាំបានផ្តល់ឱកាសដល់ថ្នាក់គ្រប់គ្រងជាន់ទាបឱ្យឈរឡើង ដើម្បីផ្តួចផ្តើមគំនិត និងអនុវត្តភាពជាអ្នកដឹកនាំ។ វាក៏ធ្វើឱ្យលេចឡើងផងដែរនូវគណៈកម្មាធិការថ្មីៗ ដែលមិនធ្លាប់មានពីមុនមក ដើម្បីដោះស្រាយបញ្ហាច្រើនវិស័យ ដូចជាពលកម្ម ការងារសិទ្ធិមនុស្ស និងវិស័យដទៃទៀត។ ដោយសារសមាជិកស្នូលភាគច្រើនគឺជាអ្នកគ្រប់គ្រងជាន់ទាប ការបង្កើតភាពជាដៃគូមានលក្ខណៈងាយស្រួល ពីព្រោះមិនមានឧបសគ្គរវាងបុគ្គល និងចិត្តគំនិត។

## កង្វះព័ត៌មាន

អ្នកឆ្លើយតបជាច្រើនបានបង្ហាញថា ការប្រាស្រ័យទាក់ទងផ្ទៃក្នុងនៅក្នុងចំណោមអង្គការទាំងឡាយ គឺជាចំណុចខ្សោយចំបងមួយ។ ជួនកាល គណៈកម្មាធិការរៀបចំ ពុំបានធ្វើការពិភាក្សាឱ្យបានច្បាស់លាស់ក្នុងលក្ខណៈជាក្រុមមួយ ហើយជារឿយៗគោលដៅ និងយុទ្ធសាស្ត្រទាំងឡាយ មើលទៅដូចជាមិនច្បាស់លាស់។ ឧទាហរណ៍ មេដឹកនាំសហជីពខ្លះពុំបានយល់ច្បាស់អំពីយុទ្ធនាការធ្វើញត្តិផ្តិតមេដៃទេ ហើយការប្រមូលស្នាមមេដៃរបស់សមាជិកទាំងឡាយកាន់តែមានភាពស្មុគស្មាញ នៅពេលដែលម្ចាស់សណ្ឋាគារជាច្រើនមិនអនុញ្ញាតឱ្យមានការប្រមូលញត្តិនៅក្នុងបរិវេណសណ្ឋាគាររបស់គេ។

## មតិមិនស៊ីសង្វាក់គ្នារបស់សហគមន៍អន្តរជាតិ និងស្ថាប័នជំនួញ

អ្នកផ្តល់ព័ត៌មាននៅក្នុងសហគមន៍ការទូត រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជន បានត្អូញត្អែរថា ទោះបីជាមានការព្រមព្រៀងគ្នាមួយក្តី ក៏សេចក្តីថ្លែងការណ៍របស់សហគមន៍អន្តរជាតិនៅមានលក្ខណៈទន់ជ្រាយ។ អ្នកផ្តល់យោបល់ដល់រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកសេចក្តីថ្លែងការណ៍នោះថា *"មានលក្ខណៈទន់ជ្រាយណាស់"* រីឯមេដឹកនាំសហជីពវិញនិយាយថា *"មានលក្ខណៈទន់ជ្រាយគួរឱ្យខកចិត្ត"*។ លើសពីនេះ គេសង្កេតឃើញថា មានអ្នកខ្លះនៅក្នុងសហគមន៍អាជីកម្ម មានមនោសញ្ចេតនាគាំទ្រដល់ការចាប់ខ្លួននោះទៅវិញ ដោយសារពួកគេយល់ថា វាជួយដល់ការគ្រប់គ្រងសណ្តាប់ធ្នាប់ និងស្ថេរភាព។

# អនុសាសន៍សម្រាប់កិច្ចប្រឹងប្រែងតស៊ូមតិនៅពេលអនាគត

អនុសាសន៍ទាំងនេះគឺសំដៅពង្រឹងក្រុមទាំងឡាយដែលចូលរួមក្នុងសកម្មភាពតស៊ូមតិ និងសមត្ថភាពរបស់ពួកគេក្នុងការបង្ហាញទស្សនៈផ្សេងៗគ្នា និងក្នុងការប្រើសន្តិវិធីដើម្បីបង្កើនលទ្ធិប្រជាធិបតេយ្យ និងការផ្លាស់ប្តូរនៅកម្ពុជា សម្រាប់រយៈពេលខ្លី ក៏ដូចជារយៈពេលវែង ។

## ជំរុញការពិភាក្សា និងវិធានការកសាងទំនុកចិត្ត ពង្រីក និងរក្សាជាប្រចាំនូវបណ្តាញទាំងឡាយ

**ពង្រឹងសម្ព័ន្ធភាពដែលទើបបង្កើតថ្មី និងសមិទ្ធផលដែលទទួលបាននៅក្នុងព្រឹត្តិការណ៍ទាំងនេះ**

ចំណងទំនាក់ទំនងថ្មីដែលត្រូវបានផ្តួចផ្តើមនៅក្នុងរយៈពេលនេះ គប្បីត្រូវបានសិក្សា និងពង្រឹងដើម្បីធ្វើឱ្យសមិទ្ធផលកាន់តែប្រសើរឡើង ។

### សកម្មភាព

- រៀបចំកិច្ចប្រជុំធំៗ ឬព្រឹត្តិការណ៍របស់ក្រុមទាំងឡាយដែលពាក់ព័ន្ធ ។
- ចងក្រងមេរៀនដែលខ្លួនបានឆ្លងកាត់កន្លងមក ។ ប្រសិនបើព្រឹត្តិការណ៍បែបនេះកើតឡើងម្តងទៀត តើសង្គមស៊ីវិលអាចមានប្រតិកម្មខុសពីនេះ ឬប្រសើរជាងនេះ?
- ពង្រឹងសមិទ្ធផលសម្រេចបានដោយ AFEC និងក្រុមស្នូលដទៃទៀត ឬគណៈកម្មាធិការរៀបចំ ។
  - ពិចារណាបង្កើតឱ្យមានប្រធានប្តូរវេនសំរាប់ AFEC ដើម្បីកុំអោយមើលទៅឃើញថាសម្ព័នភាពនេះ ជារបស់អង្គការតែមួយ ឬរបស់បុគ្គលតែម្នាក់ ។
  - បង្កើតលក្ខន្តិកៈ និងគិតគូរដើម្បីធ្វើឱ្យទៅជាផ្លូវការ នូវឋានៈស្របច្បាប់របស់សម្ព័ន្ធភាព ។

**កែលំអការពិភាក្សា និងទំនាក់ទំនងជាមួយរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ**

សង្គមស៊ីវិលចាំបាច់ត្រូវបង្កើតស្ពាន និងទំនាក់ទំនង និងកសាងទំនុកចិត្តរវាងរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងសង្គមស៊ីវិល ។ ទំនាក់ទំនងទាំងនេះប្រហែលជាអាចជួយក្នុងការទប់ស្កាត់វិវាទ នៅក្នុងករណីមានការចាប់ខ្លួននាពេលអនាគត ។

*អ្នកមិនចាំបាច់ត្រូវតែប្រឆាំងគ្រប់រឿងនោះទេ ។ ចំពោះក្រុមប្រឆាំង និងសង្គមស៊ីវិល ពេលនេះប្រការដែលសំខាន់ គឺត្រូវងាកចេញពីប្រតិកម្មដែលគេអាចទទួលយកបានកាលពីប្រាំឆ្នាំមុន ប៉ុន្តែមិនមែនបច្ចុប្បន្ននេះទេ ។ អ្នកមិនមែនមិនអាចនិយាយរកគ្នាបាននោះទេ ។* **(អ្នកឯកទេសខាងអភិបាលកិច្ចនៅកម្ពុជា)**

*យើងចាំបាច់ត្រូវមានការប្រុងប្រយ័ត្នក្នុងការប្រើការកៀបសង្កត់អន្តរជាតិរបស់យើង ......ជៀសវាងការប្រកួកប្រកាសមិនបានការ និងមានលក្ខណៈគំរាម ។ យើងចាំបាច់ត្រូវរំលឹករាជរដ្ឋាភិបាលកម្ពុជាអំពីកាតព្វកិច្ចរបស់ខ្លួនចំពោះអនុសញ្ញាអន្តរជាតិទាំងឡាយ ។ យើងគឺជាដៃគូអភិវឌ្ឍន៍ តែមិនមែនជាគូសត្រូវឡើយ ។* **(អ្នកការទូតជាន់ខ្ពស់មួយរូប)**

*សង្គមស៊ីវិលមិនចាំបាច់ចាត់ទុកខ្លួនជា "អ្នកប្រឆាំងទេ" ។ ការពិភាក្សាជាចំហថ្មីៗនេះ គឺជាសញ្ញាដ៏ល្អមួយ ។ សង្គមស៊ីវិលចាំបាច់ត្រូវមានឯករាជភាពច្បាស់លាស់ ។ កម្មវិធីសង្គមស៊ីវិលទាំងឡាយចាំបាច់ត្រូវផ្តែកលើថ្នាក់មូលដ្ឋាន ពោលគឺពួកគេមិនគួររៀបចំសិក្ខាសាលាតែនៅក្នុងក្រុងភ្នំពេញប៉ុណ្ណោះឡើយ ។ អ្នកផ្តល់ជំនួយ ចាំបាច់ត្រូវពិនិត្យវាយតម្លៃឱ្យបានញឹកញាប់លើប្រសិទ្ធភាពនៃកម្មវិធីទាំងឡាយ ។* **(សកម្មជនសិទ្ធិមនុស្សកម្ពុជា)**

## សកម្មភាព

- អង្គការសិទ្ធិមនុស្ស និងសង្គមស៊ីវិលទាំងឡាយ គប្បីស្នើសុំឱ្យមានរៀបចំការជួបប្រជុំទៀងទាត់ជាមួយរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ និងធានាឱ្យបានថា មានការផ្លាស់ប្តូរគ្នានូវព័ត៌មានជាប្រចាំ ។
- ប្រើប្រាស់ការជួបប្រជុំគ្នាជាកាលានុវត្តភាពមួយ ដើម្បីផ្តល់ និងផ្លាស់ប្តូរព័ត៌មានគ្នា ។ ការជួបប្រជុំទាំងអស់មិនសុទ្ធតែចាំបាច់ត្រូវពិភាក្សាអំពីការទាមទារឱ្យមានសកម្មភាពជាក់លាក់ឡើយ ។
- អ្នកផ្តល់ជំនួយ និងសង្គមស៊ីវិល ចាំបាច់ត្រូវតែហ៊ានពិភាក្សាអំពីបរាជ័យ ចំណុចខ្សោយ និងមេរៀនទាំងឡាយដែលបានទទួល ។
- អង្គការសង្គមស៊ីវិលទាំងឡាយ គប្បីពិភាក្សាជាមួយដៃគូរបស់ខ្លួន ជាពិសេសអង្គការទាំងឡាយនៅឯបរទេស អំពីព័ត៌មានណាដែលពួកគេត្រូវការ ( ឧទាហរណ៍ ប្រភេទ និងភាពញឹកញាប់) ។

**ឧទាហរណ៍ ១:** ភាពជាដៃគូរបស់មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ ជាមួយក្រសួងមហាផ្ទៃ លើសេចក្តីព្រាងច្បាប់ស្តីពីសេរីភាពនៃការជួបប្រជុំ បានបង្ហាញនូវការព្រមព្រៀងគ្នាក្នុងលក្ខណៈស្ថាបនា និងភាពជាដៃគូរវាងសង្គមស៊ីវិល និងរាជរដ្ឋាភិបាលកម្ពុជា ។

**ឧទាហរណ៍ ២:** វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានចំណាយពេលអស់ច្រើនឆ្នាំដើម្បីជម្រុញការពិភាក្សាគ្នាតាមរយៈកម្មវិធីទប់ស្កាត់វិវាទនៅក្នុងការបោះឆ្នោតនៅកម្ពុជា (COPCEL) ។ កម្មវិធីនេះត្រូវបានមនុស្សជាច្រើនចាត់ទុកថា ជាជោគជ័យមួយ ។

**ស្វែងរកបណ្ដាញ និងក្រុមថ្មីៗ ហើយជាពិសេសកែលំអបណ្ដាញតាមខេត្ត**

សង្គមស៊ីវិលគប្បីរិះរកវិធីផ្សេងៗ ដើម្បីគៀងគរប្រជាពលរដ្ឋ និងបណ្ដាញបន្ថែមដែលពាក់ព័ន្ធក្នុងការតស៊ូមតិ ហើយជាពិសេសគឺពង្រីកការចូលរួម និងការផ្ដល់ព័ត៌មាននៅលំដាប់ជនបទ។

### សកម្មភាព

- កែលំអបណ្ដាញថ្នាក់ខេត្ត និងការចូលរួមរបស់អង្គការទាំងឡាយនៅលំដាប់ជនបទ ៖
  - រៀបចំធ្វើវេទិកាសាធារណៈនៅតាមខេត្ត។
  - គាំទ្រប្រព័ន្ធផ្សព្វផ្សាយឯករាជ ដែលអាចចូលដល់តំបន់ជនបទ និងបង្កើនកម្លាំងផ្សាយតាមរលកធាតុអាកាស ក៏ដូចជាម៉ោងផ្សាយ។
  - ផ្ដល់លទ្ធភាពប្រើអ៊ីនធឺណិតជូនដល់អង្គការសហគមន៍ទាំងឡាយនៅតំបន់ជនបទ។
  - បកប្រែសេចក្ដីរាយការណ៍ព័ត៌មានពីភាសាបរទេស និងព័ត៌មានដទៃទៀតមកជាភាសាខ្មែរ និងចែកចាយដល់តំបន់ជនបទ។
- បង្កើនការចូលរួមរបស់ក្រុមយុវជនតាមរយៈអនុគណៈកម្មាធិការពិសេស សមាជិកភាព និងការមានតំណាងនៅក្នុងក្រុមរៀបចំផែនការទាំងឡាយ។
- ពិគ្រោះយោបល់ជាមួយសហគមន៍អាជីវកម្ម ៖ សារៈសំខាន់នៃពាណិជ្ជកម្ម និងសេដ្ឋកិច្ចចំពោះអាជ្ញាធរ និងចំពោះប្រជាពលរដ្ឋកម្ពុជា អាចមកធ្វើជាប្រធានបទពិភាក្សាបាន។
- សិក្សាពីតួនាទីរបស់ជនជាតិខ្មែរនៅបរទេស។

## ពង្រឹងស្ថាប័ន

**ងាកចេញពីរចនាសម្ព័ន្ធស្ថាប័នដែលផ្អែកលើបុគ្គល ៖**

តួអង្គទាំងឡាយនៅក្នុងអង្គការ ចាំបាច់ត្រូវមានលក្ខណៈបត់បែន និងផ្លាស់ប្ដូរទៅវិញទៅមកពីតួនាទីជាមេដឹកនាំទៅជាអ្នកដើរតាម។ អង្គការទាំងឡាយគប្បីពិភាក្សា និងពិនិត្យមើលជោគជ័យនៃការសំរេចចិត្តដែលបានធ្វើ និងកាលានុវត្តភាពដែលបានផ្ដល់ដល់អ្នកគ្រប់គ្រងថ្នាក់កណ្ដាល នៅក្នុងអំឡុងពេលដែលព្រឹត្តិការណ៍ទាំងនេះកើតឡើង ដើម្បីព្យាយាមងាកចេញពីទំនោរទៅរកថ្នាក់ដឹកនាំដែលមានលក្ខណៈបុគ្គល នៅក្នុងអង្គការ។ អ្នកដឹកនាំល្អ ធ្វើឱ្យមានអ្នកដើរតាមល្អ។

*ពួកយើង "ពឹងផ្អែកយ៉ាងច្រើន... លើមេដឹកនាំក្រុម តួអង្គបុគ្គលមួយរូប ជាជាងស្ថាប័ន ...។ ដើម្បីមានស្ថាប័នប្រកបដោយប្រសិទ្ធភាព គេត្រូវអនុវត្តវិធានទូទៅ ពោលគឺស្ថាប័នទាំងនោះត្រូវដំណើរការដោយបុគ្គលិកប្រកបដោយវិជ្ជាជីវៈដែលមានការប្ដេជ្ញាចិត្តខ្ពស់ចំពោះឧត្ដមភាព ក្នុងលក្ខណៈចំហ និងមានតម្លាភាព។"* **(អ្នកសិក្សាស្រាវជ្រាវកម្ពុជា)**

### សកម្មភាព

- ផ្តល់ការបណ្តុះបណ្តាលខាងការងារគ្រប់គ្រងដល់អ្នកគ្រប់គ្រងថ្នាក់កណ្តាល ។
- ពិចារណាលើសកម្មភាពកសាងទំនុកចិត្តសម្រាប់មេដឹកនាំថ្នាក់ខ្ពស់នៅក្នុងអង្គការ និងរវាងអង្គការ ។
- ធ្វើប្រតិភូកម្មការទទួលខុសត្រូវជូនដល់ថ្នាក់ក្រោម និងធ្វើវិមជ្ឈការដល់ការធ្វើសេចក្តីសំរេចចិត្ត ។
- ថ្នាក់គ្រប់គ្រងជាន់ខ្ពស់គប្បីសន្យាចូលរួមតែកិច្ចប្រជុំណាដែលខ្លួនអាចចូលរួមបាន និងបន្ទាប់ពីសន្យាហើយ ពុំគួរបញ្ជូនបុគ្គលិកថ្នាក់ទាបជាងខ្លួនឱ្យចូលរួមឡើយ ។

## វិធីតស៊ូមតិ

**ផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ មិនមែនលើអង្គការទេ :**

នៅក្នុងអំឡុងពេលនៃការតវ៉ានាថ្ងៃសៅរ៍នៅគុកព្រៃស និងការបញ្ចុះបញ្ចូលដើម្បីសុំឱ្យដោះលែងជនជាប់ឃុំឃាំង គេបានដាក់ជនរងគ្រោះ (ជនជាប់ឃុំឃាំង និងគ្រួសាររបស់ពួកគេ) ឱ្យឈរនៅជួរមុខនៃសកម្មភាព ដើម្បីឱ្យមានការយកចិត្តទុកដាក់ទៅលើជនទាំងនោះ និងទុក្ខលំបាករបស់ពួកគេ ជាជាងទៅលើអង្គការ ច្បាប់ និងទស្សនទានអរូបីទាំងឡាយ ។ ចំណុចនេះគឺជាយុទ្ធសាស្ត្រមួយដែលប្រើដោយអង្គការសិទ្ធិមនុស្សជាច្រើនលើសកលលោក ហើយអាចជួយទាក់ទាញការអាណិតអាសូរពីសំណាក់សាធារណជនទូទៅ ។ គេអាចស្វែងយល់ពីរបៀបបង្កើត និងប្រើប្រាស់វិធីនេះឱ្យប្រសើរបាន ។

**ប្រកាន់យកជំហរជាគោលការណ៍:**

គេអាចដកស្រង់មេរៀនពីសកម្មភាពរបស់ជនទាំងឡាយដែលចូលរួមក្នុងព្រឹត្តិការណ៍ទាំងនេះ ។ គេគប្បីត្រិះរិះពិចារណាដល់វិធានការផ្សេងទៀតដែលពាក់ព័ន្ធនឹងជំហរជាគោលការណ៍ ដូចជាជំហរសាមគ្គីភាព ដែលអាចនាំឱ្យមានដំណោះស្រាយដោយអហិង្សា ។

**ការប្រាស្រ័យទាក់ទងតាមរយៈបច្ចេកវិទ្យា**

លើកស្ទួយការផ្សព្វផ្សាយសារនៃការតស៊ូមតិតាមរយៈបច្ចេកវិទ្យា ។

### សកម្មភាព

- សិក្សាការប្រើប្រាស់ទូរស័ព្ទចល័ត ដូចជាការផ្ញើសារតាម software និងការប្រើកាមេរ៉ាទូរស័ព្ទចល័តដើម្បីថតរូបភាពដែលអាចដាក់លើទំព័រអ៊ីនធឺណិត និងដែលអាចផ្សព្វផ្សាយបាន ។
- គេអាចប្រើប្រាស់វិបសាយផ្ទាល់ខ្លួន (blog) ដើម្បីបង្កើនការផ្សព្វផ្សាយសារព័ត៌មានរបស់ប្រជាពលរដ្ឋ ។




ការផ្ញើសារតាមទូរស័ព្ទចល័តត្រូវបានប្រើដើម្បីប្រមូលការគាំទ្រពីសាធារណជន

## ការសម្របសម្រួល និងការរៀបចំផែនការធ្វើយុទ្ធនាការ

**បញ្ជូនផែនការសំរាប់កម្មវិធីពេលអនាគត និងចែករំលែកលទ្ធផលទាំងនេះដល់អង្គការដទៃទៀត ៖**

អង្គការទាំងឡាយគប្បីពិនិត្យមើលលទ្ធផល និងមេរៀនទាំងឡាយដែលទទួលបានពីព្រឹត្តិការណ៍ទាំងនេះ ហើយអនុវត្តរបៀបធ្វើផែនការសំរាប់ពេលអនាគត។ គប្បីចែករំលែករបៀបធ្វើផែនការទាំងនេះ និងការវិភាគដែលបានធ្វើ ដល់អង្គការដទៃទៀត ដើម្បីឱ្យពួកគេមានសមត្ថភាពសំរាប់ទប់ទល់នឹងព្រឹត្តិការណ៍បែបនេះ។

### សកម្មភាព

- វិភាគឧបសគ្គ និងដំណោះស្រាយដែលអាចធ្វើបាន។ ការវិភាគកាន់តែស៊ីជម្រៅលើសកម្មភាពទាំងឡាយក្នុងអំឡុងពេលនោះ ឧបសគ្គដែលអង្គការនិងបុគ្គលទាំងឡាយបានជួបប្រទះ និងដំណោះស្រាយដែលអាចធ្វើបាន អាចផ្តល់ព័តិមានដ៏មានប្រយោជន៍សំរាប់រៀបចំផែនការសកម្មភាពនាពេលអនាគត។
- សិក្សាបញ្ហាផ្លូវច្បាប់ និងធ្វើផែនការទប់ទល់ការចាប់ខ្លួនដែលអាចកើតមាន។ ប្រការនេះ គប្បីគិតទៅដល់ការទប់ស្កាត់ និងការការពារនៅពេលដែលប្រឈមមុខនឹងបញ្ហា។ ជាការសំខាន់ណាស់ដែលសកម្មជន និងអង្គការទាំងឡាយត្រូវគិតគូរដល់បញ្ហាផ្លូវច្បាប់ និងការមានអ្នកតំណាងទុកជាស្រេច មុនពេលមានសកម្មភាពផ្លូវច្បាប់ណាមួយប្រឆាំងនឹងពួកគេ។
- កែលំអវិធានការសន្តិសុខ និងការការពារ។ អ្នកផ្តល់ព័តិមានខ្លះ បានលើកឡើងពីភាពចាំបាច់ក្នុងការធ្វើផែនការជាមុនសំរាប់ពេលអនាគត ដោយមានផែនការការពារ ក៏ដូចជាផែនការសន្តិសុខ (ទាំងផ្នែករូបកាយ ឯកសារ និងអេឡិកត្រូនិក)។
- គេគប្បីធ្វើការវិភាគផ្លូវច្បាប់ជាក់ស្តែងលើការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងផលប៉ះពាល់នៃការចាប់ខ្លួនពីសំណាក់ការប្រើការចោទប្រកាន់នោះ។ ថ្វីបើរដ្ឋាភិបាលបាននិយាយថាច្បាប់នេះនឹងត្រូវកែក្តី ជាការចាំបាច់ត្រូវមានការឃ្លាំមើលយ៉ាងប្រុងប្រយ័ត្នពីសំណាក់អ្នកវិភាគច្បាប់ និងអង្គការសង្គមស៊ីវិលទាំងឡាយ។
- បង្កើតលេខាធិការដ្ឋានមួយសម្រាប់ចែករំលែកព័តិមានគ្នា។ អង្គការ ឬលេខាធិការដ្ឋានរបស់បណ្តុំអង្គការ ដែលទទួលការតែងតាំង អាចដើតួជាមូលដ្ឋាននៃព័តិមាន។
- តាមដានទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយដទៃទៀត ។ ចំណុចនេះអាចឱ្យអង្គការទាំងឡាយសង្កេតមើល ថាតើព្រឹត្តិការណ៍ទាំងនេះត្រូវគេពណ៌នាយ៉ាងដូចម្តេច និងដើម្បី ១- រាយការណ៍ពីអង្គហេតុបានច្បាស់លាស់ នូវអ្វីដែលប្រព័ន្ធផ្សព្វផ្សាយនិយាយ និង ២- រៀបចំយុទ្ធនាការព័តិមានសំរាប់ឆ្លើយបំភ្លឺ ឬកែតម្រូវព័តិមានណាដែលអាចត្រូវបានគេផ្សព្វផ្សាយខុស។

# សេចក្តីសន្និដ្ឋាន

ព្រឹត្តិការណ៍ទាំងឡាយដែលកើតឡើងក្រោយពេលចាប់ខ្លួននៅចុងឆ្នាំ ២០០៥ បាននាំមកនូវការវិវឌ្ឍជាវិជ្ជមានជាច្រើននៅក្នុងសង្គមស៊ីវិល។ ជនជាតិខ្មែរបានធ្វើការងារតាមវិធីថ្មីជាមួយសហគមន៍អន្តរជាតិ ហើយបណ្តាញជាប្រពៃណីត្រូវបានពង្រីក។

សេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំគ្នានៅប្រឈមនឹងគ្រោះថ្នាក់នៅឡើយនៅប្រទេសកម្ពុជា។ ក្នុងឆ្នាំ ២០០៥ អាជ្ញាធរបានចាប់ផ្តើមប្រើច្បាប់បរិហារកេរ្តិ៍តាំងពីសម័យអ៊ុនតាក់ ដើម្បីចាប់ខ្លួនឥស្សរជនល្បីល្បាញមួយចំនួនដាក់ពន្ធនាគារ ដោយសារអ្នកទាំងនោះបានសម្តែងទស្សនៈរបស់ខ្លួន និងដោយសារបានអនុញ្ញាតឱ្យអ្នកដទៃទៀតបានបញ្ចេញទស្សនៈរបស់គេ។ លើសពីនេះទៀត សកម្មជនដែលគេមិនស្គាល់ឈ្មោះ និងគ្មានឥទ្ធិពលជាច្រើននាក់នៅតាមខេត្ត ក៏ត្រូវបានគេចោទប្រកាន់ពីបទបរិហារកេរ្តិ៍ផងដែរ។ ទោះបីជារដ្ឋាភិបាលបានសន្យាពិនិត្យកែច្បាប់នោះក្តី ក៏បទបរិហារកេរ្តិ៍នៅតែជាបទល្មើសព្រហ្មទណ្ឌនៅឡើយ។ នៅក្នុងសេចក្តីព្រាងច្បាប់ថ្មី ស្តីពីការជួបប្រជុំជាសាធារណៈ ការតវ៉ា និងបាតុកម្មដែលគ្មានការគ្រោងទុក ត្រូវតែធ្វើឡើងនៅក្នុងទីកន្លែងកំណត់ដោយរដ្ឋាភិបាល ដោយមិនត្រូវមានអ្នកចូលរួមលើសពី ២០០ នាក់ និងមិនត្រូវមានរយៈពេលលើសពីបួនម៉ោងឡើយ។

ប្រឈមនឹងការកើនឡើងនូវការគំរាមកំហែងចំពោះសេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំគ្នា ប្រជាពលរដ្ឋខ្មែរមានសិទ្ធិទាមទារឱ្យរដ្ឋាភិបាលរបស់ខ្លួនធ្វើតាមការប្តេជ្ញារបស់ខ្លួន ក្នុងការបើកចំហលទ្ធិប្រជាធិបតេយ្យ និងដើម្បីក្លាយជាតួអង្គដូចអ្នកដទៃ នៅក្នុងកិរិតអន្តរជាតិ។